រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

007KH01A-01

អត្ថបទសិក្សា ទី ៦

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ចូរធ្វើអំណោយដោយចិត្តអំណរ

ក្នុងចំណោមបណ្តាជន មានបុរសម្នាក់ទូលព្រះយេស៊ូថា÷ «លោកគ្រូ ! សូមលោកប្រាប់បងខ្ញុំឱ្យយកកេរ្តិ៍មរតកមកចែកខ្ញុំផង» ។

ព្រះយេស៊ូមានព្រះបន្ទូលតបទៅបុរសនោះថា÷«តើនរណាបានតែងតាំងខ្ញុំអោយធ្វើជាចៅក្រមចែកទ្រព្យសម្បត្តិរបស់អ្នករាល់គ្នា ?»។ បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅបណ្តាជនថា÷ «ចូរប្រយ័ត្ន កុំលោភលន់ចង់បានទ្រព្យសម្បត្តិអោយសោះ ។ ទោះបីមនុស្សមានសម្បត្តិបរិបូណ៌យ៉ាងណាក៏ដោយ ក៏ជីវិតគេមិនអាស្រ័យនៅលើទ្រព្យសម្បត្តិឡើយ » ។

ព្រះអង្គមានព្រះបន្ទូលជាពាក្យប្រស្នាទៅគេថា÷ «មានបុរសម្នាក់ជាសេដ្ឋី ដីធ្លីរបស់គាត់បានភោគផលយ៉ាងបរិបូណ៌ ។ គាត់រិះគិតក្នុងចិត្តថា"ខ្ញុំគ្មានកន្លែងដាក់ភោគផលទាំងអស់របស់ខ្ញុំទេ តើខ្ញុំត្រូវធ្វើដូចម្តេច ?" គាត់គិតទៀតថា"ខ្ញុំត្រូវតែធ្វើយ៉ាងនេះ គឺរុះជង្រុកទាំងប៉ុន្មានរបស់ខ្ញុំចោល ហើយសង់ជង្រុកអោយធំៗជាងរួចខ្ញុំប្រមូលស្រូវ ព្រមទាំងភោគផលទាំងអស់មកដាក់ក្នុងជង្រុកថ្មីនោះ ។ បន្ទាប់មក ខ្ញុំនឹងនិយាយប្រាប់ខ្លួនខ្ញុំថា"ឱ ខ្ញុំអើយ ! មានសម្បត្តិយ៉ាងច្រើនបរិបូណ៌ បំរុងទុកចិញ្ចឹមជីវិត សំរាប់ច្រើនឆ្នាំ ខ្ញុំត្រូវសំរាក គិតតែស៊ីផឹកសប្បាយទៅ !" ។ ប៉ុន្តែ

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់សេដ្ឋីនោះថា÷ "នែ មនុស្ស ឆោតលង់អើយ ! យប់នេះយើងនឹងផ្តាច់ជីវិតអ្នកហើយ ដូច្នេះ ទ្រព្យសម្បត្តិដែលអ្នកបានប្រមូលទុកសំរាប់ខ្លួនអ្នក នឹងបានទៅជា របស់នរណាវិញ ? " » ។

ព្រះយេស៊ូមានព្រះបន្ទូលទៀតថា÷ « អ្នកណាប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់តែខ្លួនឯង ហើយគ្មានសម្បត្តិសួគ៌នៅក្នុងខ្លួន អ្នកនោះ ប្រៀបបីដូចជាសេដ្ឋីនោះដែរ » ។

(លូកា ១២:១៣-២១)

មាននាម៉ឺនម្នាក់ទូលសួរព្រះយេស៊ូថា÷« លោកគ្រូដ៏សប្បុរសអើយ! តើខ្ញុំត្រូវធ្វើអ្វី ដើម្បីអោយបានទទួលជីវិតអស់កល្បជានិច្ច ទុកជា មតិក ? » ។

ព្រះយេស៊ូមានព្រះបន្ទូលតបថា÷ « ហេតុអ្វីបានជាលោកថា ខ្ញុំ សប្បុរសដូច្នេះ ? ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ គ្មាននរណា ម្នាក់សប្បុរសឡើយ ។ លោកស្គាល់វិន័យស្រាប់ហើយថា "កុំ ប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់មនុស្ស កុំលួចទ្រព្យសម្បត្តិគេ កុំនិយាយកុហកធ្វើអោយគេមានទោស ចូរគោរពមាតាបិតា"» ។ បុរសនោះទូលព្រះយេស៊ូថា÷ « ខ្ញុំបានប្រព្រឹត្តតាមវិន័យទាំងនេះ តាំងតែពីក្មេងមក » ។

© Project WorldReach © SEAN

ព្រះយេស៊ូឮដូច្នេះ ទ្រង់មានព្រះបន្ទូលថា÷ «នៅសល់កិច្ចការមួយទៀត ដែលលោកមិនទាន់ធ្វើ គឺត្រូវយកអ្វីៗទាំងអស់ដែលលោកមានទៅលក់ ហើយចែកអោយជនក្រីក្រ ។ ធ្វើដូច្នេះ លោកនឹងបានសម្បត្តិសួគ៌ រួចសឹមអញ្ជើញមកតាមខ្ញុំចុះ » ។ ពេលនាម៉ឺននោះឮដូច្នេះ គាត់ព្រួយចិត្តយ៉ាងខ្លាំង ដ្បិតគាត់ជាអ្នកមានស្តុកស្តម្ភ ។ កាលព្រះយេស៊ូឃើញគាត់ព្រួយចិត្ត ព្រះអង្គមានព្រះបន្ទូលថា÷ «អ្នកមានពិបាកនឹងចូលទៅក្នុងព្រះរាជ្យព្រះជាម្ចាស់ណាស់ សត្វអូដ្ឋចូលតាមប្រហោងម្ជុល ងាយជាងអ្នកមានចូលទៅក្នុងព្រះរាជ្យព្រះជាម្ចាស់ទៅទៀត » ។

អស់អ្នកដែលឮព្រះបន្ទូលរបស់ព្រះអង្គពោលឡើងថា÷ «បើដូច្នេះ តើអ្នកណាអាចទទួលការសង្គ្រោះបាន ? » ។

ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា÷ «ការអ្វីដែលមនុស្សធ្វើពុំកើត ព្រះជាម្ចាស់ធ្វើកើតទាំងអស់ » ។ លោកពេត្រុសសិលាទូលព្រះអង្គថា÷ «ព្រះអង្គទតឃើញស្រាប់ហើយ អ្វីៗដែលយើងខ្ញុំមាន យើងខ្ញុំបានលះបង់ចោលទាំងអស់ ហើយមកតាមព្រះអង្គ » ។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា÷ «ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាលះបង់ផ្ទះសម្បែង ប្រពន្ធ កូន ឪពុកម្តាយ និងបងប្អូន ដោយយល់ដល់ព្រះរាជ្យព្រះជាម្ចាស់ អ្នកនោះនឹង

កំណត់ចំណាំ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ចូរដាក់ដង្វាយស្មគ្រចិត្ត និងដង្វាយដប់ភាគរយ ហើយដាក់ដង្វាយជាការជួយ និងជាពេលវេលា ។ល។...ដោយអំណរ និងដោយសប្បុរស ហើយបង្រៀនក្រុមគ្រួសាររបស់អ្នកឱ្យធ្វើដូច្នេះដែរ ។ យើងដាក់ដង្វាយសំរាប់ជួយកិច្ចការក្រុមជំនុំ កិច្ចការគ្រីស្តទូត និងសំរាប់ជួយអ្នកខ្វះខាត ។
- ប្រើរូបភាពបំភ្លឺ ដើម្បីនិយាយប្រាប់ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកពីប្រស្នាស្តីអំពីអ្នកមាន ដែលឆោតល្ងង់ និងរឿងបុរសដែលមិនដើរតាមព្រះយេស៊ូគ្រីស្ត ដោយសារតែទ្រព្យសម្បត្តិរបស់គាត់ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

ទទួលបានយ៉ាងច្រើន លើសលប់នៅពេលឥឡូវនេះ ព្រមទាំងមានជីវិតអស់កល្បជានិច្ចនៅពេលខាងមុខថែមទៀតផង » ។

(លូកា ១៨:១៨-៣០)

ហេតុអ្វីបានជាព្រះគ្រីស្តថា បុរសអ្នកមាននោះជា «មនុស្សឆោតល្ងង់ » ?

_____

_____

តើបុរសអ្នកមានម្នាក់ទៀត ស្រឡាញ់អ្វីខ្លាំងជាងព្រះយេស៊ូ ?

_____

_____

ហេតុអ្វីបានជាអ្នកមានពិបាកនឹងចូលទៅនគរស្ថានបរមសុខ ?

_____

_____

តើទ្រព្យសម្បត្តិរបស់អ្នក អាចនាំអោយអ្នកមានគ្រោះថ្នាក់ដែរឬទេ ?

_____

© Project WorldReach © SEAN

បំណងចង់ប្រមូលអោយបានអ្វីៗជាច្រើនជារបស់ខ្លួន អាចធ្វើឱ្យយើងភ្លេចពីព្រះគ្រីស្ត ។ ពួកសាវ័កលើកទឹកចិត្តយើងអោយដាក់ជង្វាយ តែមិនមែនដោយសារយើងមានកាតព្វកិច្ចត្រូវតែដាក់នោះទេ តែដោយសារយើងស្ម័គ្រចិត្តដាក់ ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកដែលធ្វើអំណោយដោយចិត្តអំណរ ។ ព្រះអង្គប្រទានពរដល់អ្នកដែលដាក់ជង្វាយដោយសប្បុរស (២ កូរិនថូស ៩:៦-៩) ។

តើអ្នកចេះដាក់ជង្វាយដោយចិត្តអំណរដែរឬទេ ? សូមសរសេរពីផែនការរបស់អ្នក :

_____

_____

_____

ព្រះយេស៊ូគង់នៅមុខហិបតង្វាយ ព្រះអង្គទតមើលរបៀបដែលបណ្តាជនយកប្រាក់មកដាក់ក្នុងហិបនោះ ។ អ្នកមានច្រើននាក់ដាក់ប្រាក់ជាច្រើន ។ មានស្ត្រីមេម៉ាយក្រីក្រម្នាក់មកដល់ នាងយកប្រាក់ពីរសេនជាចំនួនជិតិចតួចបំផុត ដាក់ក្នុងហិបតង្វាយនោះដែរ ។ ព្រះយេស៊ូត្រាស់ហៅពួកសាវ័កមក ហើយមានព្រះ-បន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាបានដឹងច្បាស់ថា

ស្ត្រីមេម៉ាយក្រីក្រនេះ បានដាក់ប្រាក់ក្នុងហិបច្រើនជាងគេទាំងអស់ ដ្បិតពួកអ្នកទាំងនោះយកប្រាក់សំណល់របស់ខ្លួនមកដាក់ ។ រីឯស្ត្រីមេម៉ាយនេះវិញ ទោះបីនាងក្រីក្រយ៉ាងណាក៏ដោយ ក៏នាងបានយកប្រាក់ដែលនាងត្រូវការជាចាំបាច់មកដាក់ដែរ គឺប្រាក់ទាំងប៉ុន្មាន ដែលនាងមានសំរាប់ចិញ្ចឹមជីវិត » ។

(ម៉ាកុស ១២:៤១-៤៤)

ព្រះយេស៊ូគ្រីស្តវាយតំលៃជង្វាយ ដែលយើងថ្វាយ យោងទៅតាមប្រាក់ដែលនៅសល់ ក្រោយការដាក់ជង្វាយ ! ។ ព្រះជាម្ចាស់នឹងប្រទានពរអោយយើង បើសិនជា :

☐ យើងដាក់ជង្វាយតែអ្វីដែលយើងនៅសល់ ក្រោយពីយើងចាយដើម្បីខ្លួនឯងសិន ។

☐ យើងថ្វាយដោយសេចក្តីស្រឡាញ់ និងដោយអំណរ ។

សូមទន្ទេញ

«ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ ទ្រង់នឹងប្រទានមកយ៉ាងបរិបូណ៌ហូរហៀរ ។ ព្រះជាម្ចាស់នឹងវាល់អោយអ្នកតាមរង្វាល់ ដែលអ្នកវាល់អោយអ្នកដទៃ » ។ *(លូកា ៦:៣៨)*